# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបិទកម្មវិធីបូជនីយចរ
# ព្រៃកប្បាស ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២០
# ធ្វើជាសាក្សីនៃជីវិតបច្ចុប្បន្ននេះ

**អត្ថបទទី១៖ អេសាយ ៥៨,៧-១០**

ត្រូវចែកអាហារឲ្យអ្នកស្រេកឃ្លាន ត្រូវទទួលជនក្រីក្រដែលគ្មានទីជម្រកឲ្យស្នាក់នៅជាមួយ បើឃើញនរណាម្នាក់គ្មានសម្លៀកបំពាក់ត្រូវចែកឲ្យគ្នាស្លៀកពាក់ផង ហើយមិនត្រូវគេចខ្លួនពីបងប្អូនណាដែលមកពឹងពាក់អ្នកឡើយ។ អស ៥៨,៧

**អត្ថបទទី២៖ កូរិនថូសទី១ ២,១-៥**

ពាក្យសម្ដីដែលខ្ញុំនិយាយ និងប្រកាស មិនមែនជាពាក្យបញ្ចុះបញ្ចូលដ៏ប៉ិនប្រសប់នោះទេ គឺព្រះវិញ្ញាណបានសម្ដែងឫទ្ធានុភាពវិញ។ ១ករ ២,៤

**ដំណឹងល្អ៖ ម៉ាថាយ ៥,១៣-១៦**

ចូរឲ្យពន្លឺរបស់អ្នករាល់គ្នា បំភ្លឺមនុស្សទាំងឡាយដូច្នោះដែរ គេនឹងឃើញអំពើល្អដែលអ្នករាល់គ្នាប្រព្រឹត្ត ហើយលើកតម្កើងសិរីរុងរឿងព្រះបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរមសុខ។ មថ ៥,១៦

បងប្អូនជាទីស្រឡាញ់!

គម្ពីរថ្ងៃនេះ យើងជាពន្លឺនៃពិភពលោក ភ្លើងដែលយើងដាក់ភ្នំដើម្បីឲ្យមនុស្សទាំងឡាយមើលឃើញបាន វាបានចូលយ៉ាងជ្រៅនៅក្នុងការរិះគិតរបស់យើង។ ម្សិលមិញយើងបានឡើងលើភ្នំ នៅពេលយើងបានដើរលើភ្នំ យើងបានឃើញទឹកដីកម្ពុជាទាំងមូល។ ពេលយើងឡើងលើភ្នំជីសូរ ជាពេលមួយយ៉ាងពិសេសដើម្បីយល់យ៉ាងជ្រៅអំពីគម្ពីរដំណឹងល្អ ព្រះយេស៊ូណែនាំឲ្យយើងទៅជាពន្លឺដែលបំភ្លឺពិភពលោក សម្រាប់យើងឲ្យយើងទៅជាពន្លឺសម្រាប់បំភ្លឺប្រទេសកម្ពុជាទាំងមូល។ នៅពេលយើងដល់លើភ្នំយើងមិនលាក់ខ្លួន ប៉ុន្តែយើងជាពន្លឺមួយដែលណែនាំឲ្យបងប្អូនទាំងអស់ ដែលកំពុងរកស៊ី ទាំងកសិករ ទាំងអ្នកនេសាទ ទាំងកម្មករ ទាំងអ្នកដែលអត់មានការងារក៏ដោយ យើងដឹងថាយើងជាពន្លឺសម្រាប់ពួកគាត់។ យើងគិតថា យើងជាមនុស្សទន់ខ្សោយ យើងជាមនុស្សដែលគ្មានសេចក្ដីក្លាហាន **តើយើងប្រកាសដំណឹងល្អដូចម្ដេចបាន?** ប៉ុន្តែលោកប៉ូលបាននិយាយថា "**ខ្ញុំមករកបងប្អូនទាំងទន់ខ្សោយ ទាំងភ័យខ្លាច ទាំងញាប់ញ័រយ៉ាងខ្លាំងក៏ប៉ុន្តែខ្ញុំប្រកាសដំណឹងល្អមិនមែនដោយនិយាយពាក្យបញ្ចុះបញ្ចូលដ៏ប៉ិនប្រសប់នោះទេ គឺដោយសម្ដែងឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ**។ សន្តប៉ូល បាននិយាយច្បាស់ គាត់ញ័រផង គាត់ភ័យ

ផង គាត់ទន់ខ្សោយផង ក៏ប៉ុន្តែគាត់ដឹងថាគាត់មិនប្រកាសដំណឹងល្អដោយពាក្យចេញពីបបូរមាត់ផ្ទាល់ខ្លួន ប៉ុន្តែគាត់សម្តែងឫទ្ធានុភាពដែលមកពីព្រះវិញ្ញាណដ៏វិសុទ្ធ។

សូមមានជំនឿលើព្រះវិញ្ញាណដ៏វិសុទ្ធ ដោយដឹងថាយើងជាយុវជនយុវនារី យើងមានសមត្ថភាពប៉ុន្មានមិនសំខាន់ជាងគេ យើងផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់ ដោយដឹងថាព្រះជាម្ចាស់ផ្ទាល់បានផ្តល់កម្លាំងកាយកម្លាំងចិត្ត ផ្តល់សេចក្តីក្លាហានឲ្យយើងទៅជាយុវជនយុវនារីដែលរស់នៅក្នុងសង្គម ដើម្បីឲ្យយើងទៅជាពន្លឺដែលមិនលាក់ខ្លួន មិនបិទទ្វារ។ អស់មួយជីវិតសូមនឹកឃើញពេលនៅលើភ្នំជីសូរ យើងជាពន្លឺដែលមានសមត្ថភាពបំភ្លឺបងប្អូនទាំងឡាយនៅជុំវិញខ្លួនយើង។ យើងមើលឃើញបងប្អូនទាំងអស់នៅលើទឹកដីរបស់យើង ដើម្បីទៅជាអំបិល និងទៅជាពន្លឺ។ ប៉ុន្តែ ប្រយ័ត្នប្រសិនបើយើងភ្លឺពេកវាចាំងភ្នែក ប្រសិនបើយើងប្រៃពេក ម្ហូបអត់ឆ្ងាញ់ទេ ដូច្នេះឲ្យយើងទៅរកមធ្យោបាយដើម្បីឲ្យយើងល្មម កុំឲ្យភ្លឺពេក កុំឲ្យប្រៃពេក។

អត្ថបទទីមួយ "**ចូរចែកអាហារឲ្យអ្នកស្រេកឃ្លាន ត្រូវទទួលជនក្រីក្រដែលគ្មានទីជម្រកឲ្យស្នាក់នៅជាមួយ បើឃើញនរណាម្នាក់គ្មានសម្លៀកបំពាក់ ត្រូវចែកឲ្យគ្នាស្លៀកពាក់ផង ហើយមិនត្រូវគេចខ្លួនពីបងប្អូនណាដែលមកពឹងផ្អែកលើយើង បើប្រព្រឹត្តបានដូច្នេះពន្លឺរបស់អ្នកនឹងលេចចេញមកដូចថ្ងៃរះ**"។ ដើម្បីទៅជាអំបិលត្រូវជាម្ហូបដែលឆ្ងាញ់បំផុត ដើម្បីទៅជាពន្លឺដែលភ្លឺយ៉ាងត្រឹមត្រូវ យើងត្រូវតែចែកអាហារឲ្យអ្នកដែលស្រេកឃ្លាន ទទួលជនក្រីក្រដែលគ្មានទីជម្រក ចែកសម្លៀកបំពាក់ដល់អ្នកដែលអត់មានអ្វីស្លៀកពាក់ មិនត្រូវគេចខ្លួនពីបងប្អូនណាដែលមកពឹងពាក់យើងឡើយ បើប្រព្រឹត្តដូច្នេះពន្លឺរបស់អ្នកនឹងលេចចេញមកដូចថ្ងៃរះ។ នេះជាគោលដៅរបស់យើងទាំងអស់គ្នា នៅក្នុងជីវិតរបស់យើងឲ្យយើងមានសកម្មភាព។ ខ្ញុំមានបួនចំណុច ដើម្បីធ្វើជាយុវជនយុវនារីដែលរួមរស់នៅក្នុងសង្គមបច្ចុប្បន្ននេះ ដោយធ្វើជាសាក្សីនៃជីវិតដែលយើងបានទទួលពីព្រះយេស៊ូគឺ៖

**ទីមួយ ឲ្យយើងទទួលស្គាល់អំពីតម្លៃថ្លៃថ្នូរនៃជីវិត** យើងជាបងប្អូនគ្នា យើងជាគ្រួសារតែមួយ យើងបាននឹកឃើញស្នាព្រះហស្តរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់បានបង្កើតផែនដី ដើមឈើ ផ្កា មេឃ និងអ្វីៗទាំងអស់ ប៉ុន្តែកំពូលនៃការបង្កើតគឺបុរសនិងស្ត្រី។ យើងដឹងថាមនុស្សទាំងអស់ បានទទួលជីវិតពីព្រះជាម្ចាស់ផ្ទាល់ អត់មានមនុស្សម្នាក់នៅលើផែនដីនេះដែលគ្មានតម្លៃ មិនសំដៅលើឋានៈរបស់គេ វណ្ណៈរបស់គេ សមត្ថភាពរបស់គេ កម្រិតសិក្សារបស់គេ តែយើងដឹងថាគេជាបុត្រធីតារបស់ព្រះជាម្ចាស់ដូចយើង។ យើងមានប្រភពនៃជីវិតតែមួយ ដែលណែនាំឲ្យយើងទាំងអស់ដឹងថាយើងមានឪពុកតែមួយគត់ គឺព្រះជាម្ចាស់ផ្ទាល់ដែលបានបង្កើតយើង។ ដូច្នេះតម្លៃថ្លៃថ្នូរនៃជីវិត មិនមែនសម្រាប់តែមនុស្សដែលមានសមត្ថភាព ដែលអស្ចារ្យ ដែលមាន

ទ្រព្យសម្បត្តិច្រើន ដែលមានចំណេះដឹង តែតម្លៃថ្លៃថ្នូរនៃជីវិតគឺសម្រាប់មនុស្សទាំងអស់។ នេះជាមូលដ្ឋានសម្រាប់ជីវិតរបស់យើងជាគ្រីស្តបរិស័ទ មនុស្សណាក៏ដោយគឺជាបុត្រធីតារបស់ព្រះជាម្ចាស់យើងត្រូវតែទទួលស្វាគមន៍គាត់ជានិច្ច។

**ទីពីរ ការសិក្សាអប់រំជាទ្រព្យសម្បត្តិដែលយើងត្រូវតែ ណែនាំឲ្យរីកចម្រើននៅក្នុងជីវិតពីមួយថ្ងៃទៅមួយថ្ងៃ** សព្វថ្ងៃយើងគិតថាមិនទៅរៀនគួរបន្ថែមយើងអត់ចេះ ប៉ុន្តែ**តើយើងបានមើលផ្ទាល់ខ្លួនឬអត់? តើយើងផ្ទាល់ខ្លួនបានយកចិត្តទុកដាក់អស់ពីសមត្ថភាពឬនូវ?** សព្វថ្ងៃយើងមានសាលាអង់គ្លេសគ្រប់ទីកន្លែង ប៉ុន្តែសិស្សានុសិស្សថ្នាក់ទី១២ ឬអ្នកចូលនៅក្នុងសាកលវិទ្យាល័យអង់គ្លេសគេខ្សោយណាស់ នេះជាបញ្ហាយើងមិនមែនមកពីគ្រូទេ។ ប្រសិនបើយើងផ្ទាល់ខ្លួនមិនយកចិត្តទុកដាក់ មិនចេះគ្រប់មុខវិជ្ជាក្រោយមកយើងប្រឡងធ្លាក់ នេះមកពីយើងដែលមិនយកចិត្តទុកដាក់ធ្វើកិច្ចការស្រាវជ្រាវផ្ទាល់ខ្លួន យើងមិនយកចិត្តទុកដាក់មើលមេរៀន។ អប់រំសិក្សាជាទ្រព្យសម្បត្តិដែលយើងមាននៅក្នុងដៃរបស់យើង សូមដឹងគុណដល់ឪពុកម្តាយដែលបានជួយកូនៗឲ្យមានការសិក្សាអប់រំសព្វថ្ងៃ។ យើងត្រូវតែទទួលខុសត្រូវផ្ទាល់ខ្លួន ដើម្បីអនាគតរបស់យើង ដោយសារសតវត្សរ៍ទី២១នេះ មិនអាចទទួលមនុស្សដែលគ្មានការសិក្សាអប់រំបានទេ។ សព្វថ្ងៃយើងមានឱកាស **តើយើងចេះចាប់យកឱកាសនេះឬអត់?** ជាពិសេសស្រីៗមានប៉ុន្មាននាក់ដែលចោលការសិក្សាដើម្បីទៅធ្វើការនៅរោងចក្រ។ នៅថ្ងៃអនាគត ស្រីៗទាំងនេះដែលចោលការសិក្សាតាំងពីបឋមសិក្សាមកម្ល៉េះ ពេលគេទៅជាម្តាយគេ គេមិនអាចជំរុញកូនគេឲ្យមានការសិក្សាថែមទៀតបានទេ ដោយសារផ្ទាល់ខ្លួនការសិក្សាខ្សោយមែនទែន។ ស្រីៗជាមេគ្រួសារ ដែលដឹកនាំគ្រួសារធ្វើឲ្យគ្រួសារមានសេចក្តីសុខ ប្រសិនបើយើងមិនភ្ញាក់ស្មារតីដើម្បីយល់ថាទ្រព្យសម្បត្តិដែលយើងមានសព្វថ្ងៃ គឺមិនមែនលុយ មិនមែនសម្ភារៈទេ ប៉ុន្តែជាការសិក្សា។ អ្នកដែលឈ្នះនៅក្នុងជីវិតនាថ្ងៃអនាគត ជាអ្នកដែលបានយកចិត្តទុកដាក់ស្រាវជ្រាវ អានសៀវភៅ យល់អំពីចំណេះដឹងទូទៅ យល់អំពីវប្បធម៌ទូទៅ យល់អំពីវប្បធម៌ផ្ទាល់ខ្លួន យល់អំពីអត្តសញ្ញាណផ្ទាល់ខ្លួន យល់អំពីខ្មែរផ្ទាល់ខ្លួន យល់អំពីពិភពលោក មើលព័ត៌មានផង អ្វីៗទាំងអស់ដែលកើតមានយើងដឹង យើងយល់ ហើយយើងស្រាវជ្រាវដើម្បីមានគំនិតថ្មីៗកែច្នៃប្រឌិតអស់ពីសមត្ថភាព។ នេះចេញពីអប់រំសិក្សាដែលយើងទទួល សីលធម៌មកពីអប់រំសិក្សា រស់នៅក្នុងសង្គមចេញពីអប់រំសិក្សាដែលយើងបានយកចិត្តទុកដាក់ទទួល។ កុំឲ្យយើងធ្វើជាមនុស្សពិការខួរក្បាល កុំឲ្យយើងធ្វើជាមនុស្សខ្វាក់ភ្នែក ផ្ទុយទៅវិញ ឲ្យយើងជាអ្នកយកចិត្តទុកដាក់យកទ្រព្យសម្បត្តិដែលព្រះជាម្ចាស់ប្រទានឲ្យ តាមរយៈអប់រំសិក្សាដើម្បីរៀបចំខ្លួននៅថ្ងៃអនាគត។

**ទីបី ថែទាំសុខភាព** សុខភាពសំខាន់ណាស់កុំឲ្យយើងយល់ខុស កុំឲ្យញ៉ាំអ្វីដែលអត់មានប្រយោជន៍។ ពីសម័យមុនយើងញ៉ាំបាយស ជាមួយត្រីសាច់តិចៗ បន្លែតិចៗ យើងអត់សូវឡើងគីឡូទេ ប៉ុន្តែឥលូវកូនក្មេងម៉ាប់ៗ ហើយឪពុកម្ដាយគេថា មើល៍!កូនខ្ញុំមានព្រលឹងណាស់ គេសប្បាយចិត្តណាស់ ក៏ប៉ុន្តែមិនមែនសាច់ដុំទេជាខ្លាញ់សុទ្ធ។ យើងត្រូវការថែរក្សាសុខភាពរបស់យើងចាប់ពីពេលនេះតទៅ ម្យ៉ាងវិញទៀតយើងឈឺដើងសូមគិតខ្លួនឯង **មូលហេតុអ្វីយើងឈឺជើង? តើមួយថ្ងៃៗយើងយកពេលវេលាប៉ុន្មាននាទីដើម្បីហាត់ប្រាណ?** បច្ចុប្បន្ននេះ សង្គមណែនាំឲ្យយើងជាមនុស្សមហាខ្ជិល យើងលែងដើរ យើងលែងជិះកង់អស់ហើយ ខ្លាចក្ដៅផង ខ្លាចហ៊ុយផង ខ្លាចទទឹកភ្លៀងផង...។ ប៉ុន្តែ នៅជប៉ុនប្រជាជនគេដើរច្រើនណាស់ នេះជាប្រទេសទំនើបបំផុតនៅក្នុងទ្វីបអាស៊ីយើង គេគិតអំពីបរិស្ថាននិងអំពីសុខភាពគេខ្លាំងណាស់។ សូមថែទាំសុខភាព កុំឲ្យពេលយើងអាយុ៥០ឆ្នាំ យើងលើសឈាមក្រោយមកពិការមួយចំហៀងខ្លួន ឬមានបញ្ហាសុខភាពផ្សេងៗ។

**ទីបួន បរិស្ថាន** នេះជាទ្រព្យសម្បត្តិដែលយើងបានទទួលពីព្រះជាម្ចាស់ ពេលយើងនៅលើភ្នំជីសូរ យើងឃើញបរិស្ថានរបស់យើងស្អាតណាស់។ ពេលយើងមើលព្រះអាទិត្យរះ យើងយល់ថានេះជាព្រះជាម្ចាស់ ដែលណែនាំឲ្យពន្លឺរបស់ព្រះអង្គរះនៅលើផែនដីរបស់យើង ដើម្បីឲ្យមនុស្សទាំងអស់ទទួលពន្លឺនេះ។ រៀងៗខ្លួនយើងអាចទៅជាពន្លឺសម្រាប់បងប្អូនឯទៀតៗ លុះត្រាតែយើងយកចិត្តទុកដាក់ថែរក្សាបរិស្ថាន ថែរក្សាទឹកដីរបស់យើងដែលជាទ្រព្យសម្បត្តិ។ សព្វថ្ងៃ តាមការវាយតម្លៃនៅក្នុងខែកក្កដាប្រចាំឆ្នាំ យើងស៊ីទ្រព្យសម្បត្តិនៃផែនដីអស់ហើយ មានន័យថាយើងជំពាក់ផែនដី ដោយសារមានទ្រព្យសម្បត្តិមួយចំនួនដែលកើតមិនទាន់។ យើងជំពាក់ទ្រព្យសម្បត្តិរបស់ផែនដីសម្រាប់ឆ្នាំក្រោយៗ រហូតកូនចៅរបស់យើងអស់ហើយ អស់អុកស៊ីសែនធ្វើឲ្យមនុស្សយើងនឹងដាច់ខ្យល់ ពេលនោះផែនដីរបស់យើងទៅជាដីកប់សព។

ដូច្នេះ យើងជាយុវជនយុវនារី យើងត្រូវតែទទួលស្គាល់តម្លៃថ្លៃថ្នូរនៃជីវិត យកចិត្តទុកដាក់នៅក្នុងអប់រំសិក្សា ថែទាំសុខភាព ស្រឡាញ់បរិស្ថាន និងផ្ដល់សាក្ខីភាពអំពីជំនឿរបស់យើង ជាគ្រីស្តបរិស័ទ ជាសាវ័ករបស់ព្រះគ្រីស្ត ជាបុត្រធីតារបស់ព្រះជាម្ចាស់។ អាម៉ែន៕